ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.៥១៣...០២៣...០០១...ប្រកសព័ត៌មាន

*ថ្ងៃសុក្រ ១៤រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣

នៅថ្ងៃព្រហស្បតិ៍ ១៣រោច និងថ្ងៃសុក្រ ១៤រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៩-២០ ខែមករា ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជាបានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣ នៅអគារធនាគារជាតិនៃកម្ពុជា សែនសុខ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា។ សន្និបាតប្រចាំឆ្នាំ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីអបអរសាទរ និងផ្សព្វផ្សាយអំពីលទ្ធផលដែលធនាគារជាតិនៃកម្ពុជាសម្រេចបាននៅក្នុងឆ្នាំ២០២២កន្លងមក ព្រមទាំងទស្សនវិស័យនិងទិសដៅការងារសម្រាប់ឆ្នាំ២០២៣។ ថ្នាក់ដឹកនាំនិងមន្ត្រីជំនាញបានបង្ហាញពីលទ្ធផលដែលសម្រេចបាន បញ្ហាប្រឈម និងទិសដៅការងារដើម្បីសម្រេចបានលទ្ធផលល្អប្រសើរនាឆ្នាំខាងមុខ។

នៅឆ្នាំ២០២២នេះ ប្រព័ន្ធធនាគារកម្ពុជាសម្រេចបានលទ្ធផលល្អ និងបានរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងគាំទ្រកំណើនសេដ្ឋកិច្ច ដែលត្រូវបានប៉ាន់ស្មានថាងើបឡើងវិញក្នុងអត្រា ៥,១%។ ក្នុងស្ថានភាពដែលថ្លៃប្រេងឥន្ធនៈពិភពលោកបានកើនឡើង ក្រោមឥទ្ធិពលនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន គោលនយោបាយរូបិយវត្ថុត្រូវបានអនុវត្តឡើងដោយប្រុងប្រយ័ត្ននិងបត់បែនតាមរយៈការគ្រប់គ្រងសន្ទនីយភាពក្នុងកម្រិតសមស្រប ដោយថ្លឹងថ្លែងពីការរក្សាអត្រាប្តូរប្រាក់ឱ្យមានស្ថិរភាពនិងឆ្លើយតបនឹងតម្រូវការសាច់ប្រាក់របស់សេដ្ឋកិច្ច។ ជាក់ស្តែង អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកត្រូវបានរក្សាឱ្យមានស្ថិរភាពក្នុងរង្វង់ ៤.១០២រៀល ក្នុង១ដុល្លារអាមេរិក ហើយអត្រាអតិផរណាប្រចាំឆ្នាំ២០២២ មានកម្រិត ៥,៤%។ ទុនបម្រុងអន្តរជាតិបានថយចុះបន្តិចដោយសារការប្រែប្រួលនៃទីផ្សារហិរញ្ញវត្ថុអន្តរជាតិនិងការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិក ប៉ុន្តែបន្តស្ថិតក្នុងកម្រិតខ្ពស់គ្រប់គ្រាន់ ដែលស្មើនឹង ៧ខែ នៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់ខ្ពស់ជាងកម្រិតអប្បបរមា ៣ខែ ដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន។

ឆ្លើយតបនឹងកំណើនតម្រូវការហិរញ្ញប្បទានសម្រាប់ទ្រទ្រង់ការងើបឡើងវិញនៃសេដ្ឋកិច្ច ប្រព័ន្ធធនាគារបានផ្តល់ឥណទានទៅកាន់វិស័យឯកជន ជាមួយអត្រាកំណើន ២១% ដោយបានបែងចែកទៅគ្រប់វិស័យ ជាពិសេសវិស័យផលិតកម្ម ដូចជា កម្មន្តសាលនិងកសិកម្ម។ ក្រោយពីបានបញ្ចប់ការរៀបចំឥណទានឡើងវិញ អនុបាតឥណទានមិនដំណើរការបានកើនឡើងបន្តិចដល់ប្រមាណ ៣% ប៉ុន្តែស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញវិធានការគាំទ្រដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាពិសេសបានអនុញ្ញាតឱ្យគ្រឹះស្ថានប្រើប្រាស់ទ្រនាប់



ប្រអប់សំបុត្រលេខ ២៥, អគារលេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥១៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ដើមទុនខនស៊ើវេសិនបានទាំងស្រុង (១០០%) ដើម្បីបង្កើនលទ្ធភាពក្នុងការធ្វើសំវិធានធនដោយមិនប៉ះពាល់ដល់ដើមទុន។ ប្រឈមនឹងហានិភ័យដែលកំពុងកើតឡើងនៅក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ការត្រួតពិនិត្យក៏ត្រូវបានពង្រឹង ដោយផ្អែកលើហានិភ័យនិងទស្សនអនាគត និងការធ្វើស្រ្តេសតេស្តលើភាពធន់នៃប្រព័ន្ធធនាគារ ដើម្បីដាក់ចេញនូវវិធានការបុរេសកម្ម សំដៅគ្រប់គ្រងហានិភ័យនិងរក្សាស្ថិរភាពហិរញ្ញវត្ថុ។ ម៉្យាងទៀត បរិយាបន្នហិរញ្ញវត្ថុ ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន ត្រូវបានបន្តជំរុញជាលំដាប់ ដោយអត្រាប្រជាជនកំពុងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការមានកម្រិត ៦៧% ដែលកើនពី ៥៩% នៅឆ្នាំ២០១៥ ហើយការប្រើប្រាស់សេវាហិរញ្ញវត្ថុក្រៅផ្លូវការមានកម្រិត ៣% ដែលថយចុះពី ១២% ក្នុងអំឡុងពេលដូចគ្នា។

ស្របពេលដែលបច្ចេកវិទ្យាហិរញ្ញវត្ថុបានរីកចម្រើនយ៉ាងឆាប់រហ័ស ហើយការដោះដូរតាមអនឡាញក៏មានភាពពេញនិយម ប្រព័ន្ធទូទាត់ត្រូវបានធ្វើទំនើបកម្មជាបន្តបន្ទាប់ ដើម្បីសម្រួលដល់ការទូទាត់នៅក្នុងសេដ្ឋកិច្ច ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងឆាប់រហ័ស។ ប្រសិទ្ធភាពនិងភាពងាយស្រួលនៃប្រព័ន្ធទូទាត់បានបង្កើនចំនួនប្រជាជនប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិកយ៉ាងឆាប់រហ័ស ដោយទំហំប្រាក់ប្រតិបត្តិការទូទាត់សងប្រាក់បានកើនឡើងដល់ប្រមាណ ២៧២,៥០ ប៊ីលានដុល្លារអាមេរិក និងចំនួនគណនីអ៊ីវ៉ាឡេតបានកើនដល់ ១៧,៩ លាន។ ជោគជ័យក្នុងការអភិវឌ្ឍប្រព័ន្ធទូទាត់បានលើកមុខមាត់កម្ពុជានៅលើឆាកអន្តរជាតិចំពោះភាពច្នៃប្រឌិតនិងនវានុវត្តន៍ខ្ពស់ ដោយមានប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនបានស្នើសុំសិក្សាបទពិសោធន៍ពីកម្ពុជា។

នៅឆ្នាំ២០២៣ សេដ្ឋកិច្ចពិភពលោកអាចប្រឈមនឹងការថយចុះល្បឿនកំណើនថែមទៀត ធៀបនឹងឆ្នាំ២០២២ ដោយសារហានិភ័យដែលបាននិងកំពុងកើតឡើង។ ដោយឡែក កំណើនសេដ្ឋកិច្ចកម្ពុជារំពឹងដោយសុទិដ្ឋិនិយមថាអាចកើនក្នុងអត្រា ៦% ជាមួយនឹងអត្រាអតិផរណា ២,៥%។ ដើម្បីបន្តគាំទ្រការងើបឡើងនៃសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជានឹងបន្តចូលរួមគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការស្តារនិងកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច សំដៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ នយោបាយរូបិយវត្ថុនឹងបន្តអនុវត្តប្រកបដោយបុរេសកម្ម និងប្រុងប្រយ័ត្ន ហើយយុទ្ធសាស្រ្តចាកចេញពីវិបត្តិនឹងត្រូវធ្វើឡើងតាមការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពង្រឹងទ្រនាប់គោលនយោបាយសម្រាប់ឆ្លើយតបនឹងការប៉ះទង្គិចជាយថាហេតុនាពេលអនាគត។ ប្រព័ន្ធទូទាត់នឹងត្រូវបន្តធ្វើទំនើបកម្ម ដោយបង្កើនប្រតិបត្តិការអន្តរគ្រឹះស្ថាន និងការតភ្ជាប់ជាមួយប្រទេសក្នុងតំបន់។ ម្យ៉ាងទៀត ប្រព័ន្ធធនាគារកម្ពុជានឹងបន្តលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន ព្រមទាំងអនុវត្តគោលការណ៍ហិរញ្ញប្បទានបៃតងនិងប្រកបដោយចីរភាព តាមរយៈការផ្តល់ហិរញ្ញប្បទានដល់គម្រោងវិនិយោគដែលគិតគូរដល់គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG)។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥)២៣ ៩៨០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh
**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.org.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA